ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៣៣..៩៧.ខ...

# សារលិខិត

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ផ្ញើជូនវេទិកានិពន្ធនាយកសារព័ត៌មានកម្ពុជា ស្តីពី "សារព័ត៌មានកម្ពុជា ក្នុងយុគសម័យ៤.0" នាថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១៩

លោកនិពន្ធនាយកទាំងអស់ជាទីស្រឡាញ់រាប់អាន!

ថ្ងៃនេះខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង តាងនាមឱ្យរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមចូលរួមអបអរសាទរវេទិកានិពន្ធនាយកសារព័ត៌មានកម្ពុជាដែលក្លឹបអ្នកកាសែតកម្ពុជាបានរៀបចំឡើងជារៀងរាល់ឆ្នាំក្នុងគោលបំណងលើកស្ទួយសិទ្ធិសេរីភាពខាងសារព័ត៌មានដែលធានាដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់ស្តីពីរបបសារព័ត៌មានស្របតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យ សេរី ពហុបក្ស ដើម្បីលើកកម្ពស់ការអភិវឌ្ឍសមត្ថភាពយល់ដឹងនិងការទទួលខុសត្រូវផ្នែកវិជ្ជាជីវៈ គុណភាព ប្រសិទ្ធភាព និងតម្លៃនៃសារព័ត៌មាន ព្រមទាំងចូលរួមចំណែកថែរក្សាសុខសន្តិភាព និងការអភិវឌ្ឍយូរអង្វែងនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

វេទិកានិពន្ធនាយកសារព័ត៌មានកម្ពុជា ឆ្នាំ២០១៩ បានលើកយកប្រធានបទស្តីពី «សារព័ត៌មានកម្ពុជាក្នុងយុគសម័យ៤.០» គឺពិតជាមានសារសំខាន់ណាស់ស្របទៅនឹងនិន្នាការសកល ដែលកំពុងបញ្ចូលបច្ចេកវិទ្យាឌីជីថលទៅក្នុងបដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤ ដើម្បីឱ្យបងប្អូនអ្នកសារព័ត៌មានរបស់យើងបានសិក្សាស្វែងយល់និងចែករំលែកចំណេះដឹងអំពីគុណសម្បត្តិនិងគុណវិបត្តិនៃការវិវត្តបច្ចេកវិទ្យាទំនើបផ្នែកប្រព័ន្ធផ្សព្វផ្សាយនាពេលបច្ចុប្បន្ន ក្នុងគោលដៅជំរុញការធ្វើឌីជីថលភាវូបនីយកម្មប្រព័ន្ធផ្សព្វផ្សាយទៅក្នុងទីផ្សារឱ្យកាន់តែមានសក្តានុពលខ្លាំងក្លាថែមទៀត និងបង្កើនកិច្ចសហការផ្លាស់ប្តូរព័ត៌មានការបណ្តុះបណ្តាលធនធានមនុស្សឱ្យដើរទាន់ការវិវត្តនៃបច្ចេកវិទ្យាប្រព័ន្ធផ្សព្វផ្សាយទំនើប ព្រមទាំងរិះរកវិធានការទប់ស្កាត់ និងលុបបំបាត់ព័ត៌មានក្លែងក្លាយ ដែលកំពុងគំរាមកំហែងយ៉ាងធ្ងន់ធ្ងរលើសិទ្ធិបុគ្គលឯកជនដែលត្រូវបានការពារដោយច្បាប់រដ្ឋ សន្តិសុខជាតិ និងស្ថិរភាពនយោបាយនៅកម្ពុជា ក៏ដូចជានៅ

ក្នុងតំបន់ និងនៅលើសកលលោក ដែលកើតចេញប្រព័ន្ធផ្សព្វផ្សាយឌីជីថលនៃបដិវត្តន៍ឧស្សាហកម្មទី៤។

ក្រៅពីបញ្ហាប្រឈមទៅនឹងព័ត៌មានក្លែងក្លាយដែលសកលលោកកំពុងព្រួយបារម្ភ ស្ថាប័នសារព័ត៌មានរបស់យើងត្រូវខិតខំប្រឹងប្រែងអភិវឌ្ឍចំណេះដឹងថែមទៀត ទាំងសមត្ថភាពយល់ដឹងនៃការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលសម្រាប់ផលិតព័ត៌មាន ការរក្សាទុកទិន្នន័យនិងបញ្ជូនព័ត៌មានទាំងសមត្ថភាពវិភាគព័ត៌មានក្នុងនិងក្រៅប្រទេសឱ្យបានស៊ីជម្រៅកម្រិតអន្តរជាតិ និងការចែករំលែកព័ត៌មានបានរហ័សទាន់សភាពការណ៍ប្រកបដោយការទទួលខុសត្រូវខ្ពស់ដែលអាចទុកចិត្តបានព្រមទាំងជំរុញការអភិវឌ្ឍទីផ្សារប្រព័ន្ធផ្សព្វផ្សាយឌីជីថលឱ្យបានសមស្របទាន់សភាពការណ៍វិវត្តនៃបច្ចេកវិទ្យាឌីជីថល ដើម្បីឆ្លើយតបទៅនឹងការប្រកួតប្រជែងទីផ្សារលើវិស័យព័ត៌មានរវាងសារព័ត៌មានប្រពៃណីជាមួយសារព័ត៌មានសម័យថ្មី ក៏ដូចជាការប្រកួតប្រជែងរវាងវិស័យសារព័ត៌មានសម័យថ្មីជាមួយបណ្តាញផ្សព្វផ្សាយសង្គម ដែលកំពុងដណ្តើមទីផ្សារនាពេលបច្ចុប្បន្ន។

**បងប្អូនអ្នកសារព័ត៌មានទាំងអស់ជាទីស្រឡាញ់រាប់អាន**

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមសម្តែងនូវការកោតសរសើរដោយស្មោះចំពោះបងប្អូនអ្នកសារព័ត៌មានយើងមួយចំនួនធំដែលបានខិតខំពុះពាររាល់ការលំបាកបំពេញការងាររបស់ខ្លួនយ៉ាងសកម្មប្រកបដោយភាពស្មោះត្រង់តាមវិជ្ជាជីវៈនិងមានការទទួលខុសត្រូវខ្ពស់ក្នុងការផ្សព្វផ្សាយនិងចែករំលែកព័ត៌មានជូនប្រជាពលរដ្ឋបានដឹង និងស្វែងយល់អំពីសភាពការណ៍ពិតនៅកម្ពុជា និងការប្រែប្រួលស្ថានការណ៍នយោបាយនៅលើសកលលោក ដែលទាមទារឱ្យអ្នកសារព័ត៌មានធ្វើការឆ្លើយតបបានទាន់សភាពការណ៍ ដើម្បីបំពេញសេចក្តីត្រូវការចង់ដឹង ចង់ស្វែងយល់អំពីសភាពការណ៍វិវត្តនៅលើសកលលោក ទាំងបញ្ហានយោបាយសេដ្ឋកិច្ច សង្គម ទាំងបញ្ហាផ្សេងៗទៀត ដែលទាក់ទងទៅនឹងជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគេ។

ទន្ទឹមនេះ ក៏សូមកោតសរសើរដល់បងប្អូនអ្នកសារព័ត៌មាន និងអង្គភាពសារព័ត៌មានមួយចំនួនធំដែលបានខិតខំប្រឹងប្រែងធ្វើការបកស្រាយពន្យល់ឆ្លើយតបនឹងការប្រើប្រាស់ព័ត៌មានក្លែងក្លាយរបស់ក្រុមឧទ្ទាមក្រៅច្បាប់និងពួកឱកាសនិយមដែលមានបរទេសនៅពីក្រោយខ្នងតាមរយៈប្រព័ន្ធផ្សព្វផ្សាយនានានិងបណ្តាញទំនាក់ទំនងសង្គមក្នុងបំណងបំពុលបរិយាកាសសង្គមប្រឆាំងនឹងរាជរដ្ឋាភិបាលកម្ពុជា ជូនជនរួមជាតិនិងអន្តរជាតិបានជ្រួតជ្រាបអំពីសភាពការណ៍ពិតនៅកម្ពុជា ព្រមទាំងទប់ស្កាត់បានទាន់ពេលវេលានូវរាល់ឧបាយកលដ៏ពិសពុលរបស់ពួកគេដែលប៉ុនប៉ងផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់ និងអូសទាញប្រទេសកម្ពុជាឱ្យធ្លាក់ចូលទៅក្នុងភ្លើងសង្គ្រាមសារជាថ្មី។

បេសកកម្មរបស់បងប្អូនអ្នកសារព័ត៌មាននិងស្ថាប័នសារព័ត៌មាន គឺពិតជាមានសារសំខាន់ក្នុងការចូលរួមចំណែកយ៉ាងសកម្មក្នុងការថែរក្សាសុខសន្តិភាព ស្ថិរភាពនយោបាយ ការអភិវឌ្ឍប្រទេសជាតិប្រកបដោយចីរភាព និងការពារការរស់ឡើងវិញរបស់ប្រជាជនកម្ពុជា ព្រមទាំងលើកស្ទួយលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជាយ៉ាងពិតប្រាកដ។ កត្តាទាំងនេះហើយដែលរាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាចិត្តក្នុងការលើកកម្ពស់ភាពជាដៃគូដែលមិនអាចខ្វះបានជាមួយសារព័ត៌មាន ក្នុងក្របខ័ណ្ឌប្រទេសប្រកាន់របបប្រជាធិបតេយ្យសេរីពហុបក្ស។

ជាថ្មីម្តងទៀត ខ្ញុំសូមបញ្ជាក់ជូនថា រាជរដ្ឋាភិបាលតែងតែយកចិត្តទុកដាក់ក្នុងការលើកកម្ពស់សិទ្ធិសេរីភាពខាងការបញ្ចេញមតិ សេរីភាពខាងសារព័ត៌មាន ហើយបានផ្តល់អាទិភាពជាចម្បងនៅក្នុងកម្មវិធី

នយោបាយយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលទាំងនៅក្នុងដំណាក់កាលទីបី និងដំណាក់កាលទីបួន ដល់វិស័យសារព័ត៌មានក្នុងការចូលរួមចំណែកជាមួយរាជរដ្ឋាភិបាល ក្នុងការប្រឆាំងអំពើពុករលួយ ការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ការកែទម្រង់រដ្ឋបាលសាធារណៈ ការលើកស្ទួយលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ដើម្បីកសាងសង្គមមួយប្រកបដោយភាពយុត្តិធម៌ សុខសន្តិភាព និងការអភិវឌ្ឍយូរអង្វែង ដែលជាបំណងប្រាថ្នា និងជាចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា។

ក្នុងន័យនេះ រាជរដ្ឋាភិបាលកម្ពុជា ពិតជាត្រូវការស្ថាប័នសារព័ត៌មានដែលមានថាមពលប្រកបដោយការទទួលខុសត្រូវខ្ពស់និងមានភាពស្មោះត្រង់ចំពោះវិជ្ជាជីវៈ ដែលតម្រូវឱ្យអ្នកសារព័ត៌មានរបស់យើងស្តាប់គ្រប់សំឡេងភាគីពាក់ព័ន្ធ ហ៊ាននិយាយការពិត ហ៊ានរិះគន់ក្នុងន័យស្ថាបនា និងហ៊ានទទួលយកការពិត ហើយធ្វើការឆ្លុះបញ្ចាំងឱ្យឃើញគ្រប់តថភាពសង្គមនិងជៀសវាងការផ្សព្វផ្សាយព័ត៌មានតែមួយជ្រុងឬព័ត៌មានក្លែងក្លាយបំប៉ោងសភាពការណ៍ ញុះញង់ឱ្យមានជម្លោះផ្ទៃក្នុងរុញច្រានប្រទេសឱ្យធ្លាក់ក្នុងភាពវឹកវរ អសន្តិសុខឬបង្កឱ្យកើតមានជម្លោះប្រដាប់អាវុធជាមួយប្រទេសជិតខាងធ្វើឱ្យអន្តរាយដល់ប្រទេសជាតិ ដើម្បីបានផលប្រយោជន៍ផ្ទាល់ខ្លួន។

មុននឹងបញ្ចប់ ខ្ញុំសូមអំពាវនាវដល់បងប្អូនអ្នកសារព័ត៌មានជាតិនិងអន្តរជាតិ ដែលកំពុងបំពេញបេសកកម្មលើវិស័យព័ត៌មាននៅក្នុងព្រះរាជាណាចក្រកម្ពុជា សូមយកចិត្តទុកដាក់អនុវត្តការកិច្ចឱ្យបានត្រឹមត្រូវតាមវិជ្ជាជីវៈសារព័ត៌មាន និងខិតខំអភិវឌ្ឍសមត្ថភាពរបស់ខ្លួនបន្ថែមទៀត ទាំងសមត្ថភាពផ្នែកជំនាញបច្ចេកទេស ទាំងសមត្ថភាពការផលិតព័ត៌មាន និងការវិភាគព័ត៌មានឱ្យបានស៊ីជម្រៅកម្រិតអន្តរជាតិ ដើម្បីឆ្លើយតបទៅនឹងការវិវត្តនៃបច្ចេកវិទ្យានិងការប្រកួតប្រជែងទីផ្សារឱ្យកាន់តែមានសក្តានុពលថែមទៀត ព្រមទាំងរិះរកវិធានការទប់ស្កាត់ បន្សាបរាល់ព័ត៌មានក្លែងក្លាយ ដែលកំពុងគំរាមកំហែងយ៉ាងធ្ងន់ធ្ងរលើសិទ្ធិបុគ្គលឯកជន សន្តិសុខជាតិ និងស្ថិរភាពនយោបាយនៅកម្ពុជា។

ទីបញ្ចប់ ខ្ញុំសូមជូនពរបងប្អូនអ្នកសារព័ត៌មានជាតិ និងអន្តរជាតិទាំងអស់ដែលកំពុងបំពេញបេសកកម្មទាំងនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងនៅបរទេសទទួលបានជោគជ័យក្នុងការបំពេញភារកិច្ចរបស់ខ្លួន និងសូមប្រកបដោយពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃព្រហស្បតិ៍ ៩កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**